# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦

## កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2016

## (មហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ី)

តបតាមការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន សិស្សានុសិស្សវិទ្យាល័យកម្ពុជាចំនួន ៩រូបនឹងធ្វើទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនពីថ្ងៃទី២៣ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ក្រោមកម្មវិធីបណ្តាញផ្លាស់ប្តូរសិស្ស និស្សិតនិងយុវជនអាស៊ីខាងកើត ហៅកាត់ថា JENESYS 2016។

សិស្សនិស្សិត៩រូបនឹងធ្វើទស្សនកិច្ចទៅកាន់ទីក្រុងគីតាមី ខេត្តហុកកៃដូ ដើម្បីចូលរួមមហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ី២០១៦ ដែលនឹងធ្វើឡើងនៅថ្ងៃទី២៦ ខែវិច្ឆិកា ខាងមុខ។ ភាពយន្តខ្នាតខ្លីចំនួន៣រឿង ផលិតឡើងដោយសិស្សចំនួន៩រូប ត្រូវជ្រើសរើសក្នុងចំណោមភាពយន្តចំនួន៤៦រឿង នាវគ្គប្រកួតពាក់កណ្តាលផ្តាច់ព្រ័ត្រនៅក្នុងប្រទេស ដែលបានរៀបចំឡើងដោយស្ថានទូតជប៉ុននៅកម្ពុជា រួមសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលសហប្រតិបត្តការកម្ពុជា-ជប៉ុន និងបានជ្រើសតាំងឡើងសម្រាប់មហោស្រពខាងលើ។

សិស្សានុសិស្សនឹងមានឱកាសសាកល្បងកីឡាឃើលីង (curling) ដែលជាកីឡាដ៏ល្បីល្បាញមួយក្នុងរដូវរងារ ក៏ដូចជាការធ្វើដំណើរកំសាន្តក្នុងទីក្រុង និងកម្មវិធីផ្លាស់ប្តូរនៅវិទ្យាល័យនិងមហាវិទ្យាល័យមួយនៅក្នុងទីក្រុងគីតាមី។ ចំពោះកម្មវិធីលម្អិត គឺមានភ្ជាប់ជាមួយសេចក្តីប្រកាសព័ត៌មាននេះ។

កម្មវិធី JENESYS រៀបចំឡើងក្នុងគោលបំណងជម្រុញនូវទំនុកចិត្តនិងការយល់ដឹងពីគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុននិងបណ្តាប្រទេសនិងតំបន់ដែលបានចូលរួម ព្រមទាំងកសាងមូលដ្ឋាននៃចំណងមិត្តភាពនិងសហប្រតិបត្តិការក្នុងពេលអនាគត។ តាមរយៈកម្មវិធីនេះ ក្រសួងការបរទេសបានអញ្ជើញយុវជនកម្ពុជាជាង២០០០រូបហើយតាំងពីឆ្នាំ២០០៧មក។

យើងខ្ញុំសង្ឃឹមថា អ្នកចូលរួមនានានឹងអាចយល់ដឹងកាន់តែជ្រាលជ្រៅអំពីប្រទេសជប៉ុន ហើយពួកគេអាចចែករំលែកបទពិសោធរបស់គេអោយបានកាន់តែទូលំទូលាយ ជាមួយប្រជាជនកម្ពុជា បន្ទាប់ពីពួកគេវិលត្រលប់មកវិញ។

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162; Email: info.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*